ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០១៨

**សេចក្តីផ្តើម**:

នៅក្នុងខែកក្កដានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**:

**១.មុខងារនីតិកម្ម**:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០១លើក ប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ចំនួន០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០២ច្បាប់។ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់-ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤<br>- បានសម្អាត តុបតែងសាល ផ្គត់ផ្គង់ និងផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗ សរុបចំនួន០៥លើក មានអ្នកចូលរួមចំនួន២៥២នាក់<br>- បានថតចម្លងឯកសារចំនួន១,២៩៥ច្បាប់ អស់ក្រដាសចំនួន១៦,២២៣សន្លឹក<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១៦លើក |

| | |
|---|---|
| | - បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នចំនួន១៨២នាក់ ស្មើនឹង០៤លើក<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗចំនួន៤៧ច្បាប់<br>- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗចំនួន២០៨ច្បាប់ ពីក្រសួង ស្ថាប័ននានា និងចាត់ចែងតាមនីតិវិធី<br>- បានសិក្សាស្រាវជ្រាវ និងធ្វើឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០២ច្បាប់<br>- បានស្រាវជ្រាវ បកប្រែ និងសង្ខេបព័ត៌មានសភាអន្តរជាតិបានចំនួន៦០ច្បាប់<br>- ប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន០១លើក<br>- បានថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មានចំនួន០៩លើក។ |

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំជ្រៃឃ្មុំ ឃុំត្នោតទី១ ឃុំត្នោតទី២ និងឃុំរំលេច សរុបចំនួន២៥នាក់ ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាព ចែករំលែក និងផ្តល់ព័ត៌មានស្តីពី នីតិវិធីនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នីតិកាលទី៦ នៅ | - បានធ្វើលិខិតបេសកកម្ម ជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៩នាក់ ស្មើនឹង០២ច្បាប់។ |

| | |
|---|---|
| សាលាឃុំព្រៃឃ្នៀ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង។ | |

**៣.មុខងារតំណាង:**

| វេទនាសម្ព័ន្ធនយោបាយ | វេទនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា៖<br>+ អញ្ជើញជាកិត្តិយសក្នុងព្រះរាជពិធីបុណ្យរុក្ខទិវា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណា ព្រះបាទសម្ដេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅស្ថានីយ៍ដាំកូនឈើថ្មរូង ភូមិព្រែកអំពិល ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត<br>+ អញ្ជើញជាអធិបតីក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី ពិធីកាត់ឫសសីមាព្រះវិហារ និងពិធីសម្ពោធឧបដ្ឋានសាលា ព្រមទាំងសម្ពោធធ្នង់សមិទ្ធផលនានា នៅវត្តព្រះពុទ្ធនិព្វាន វត្តព្រៃក្ដួច និងវត្តភ្នំទំពែក នៅខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងខេត្តកណ្ដាល<br>+ អញ្ជើញចុះសាកសួរសុខទុក្ខ និងជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំចាស់ជរា ប្រជាពលរដ្ឋតាមខ្នងផ្ទះ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស ព្រមទាំងបានចាក់គ្រួសក្នុងបរិវេណអនុវិទ្យាល័យព្រះពុទ្ធ នៅខេត្តកណ្ដាល និងរាជធានីភ្នំពេញ<br>+ អញ្ជើញចូលរួមពិសាអាហារសាមគ្គី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយក- | - រៀបចំបែបបទ ផ្ដល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាគណៈអធិបតីក្នុងពិធីផ្លូវការផ្សេងៗសរុបចំនួន៥៤៩លើក<br>- បានផ្ដល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងការចុះបេសកកម្មអមដំណើរក្រុមសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញអមដំណើរជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ និងសាកសួរសុខទុក្ខកម្មកររោងចក្រ ជួបសំណេះសំណាល ពិភាក្សាការងារ ស្ដាប់សំណូមពររបស់ក្រុមប្រឹក្សាឃុំ និងពិធីសម្ពោធអណ្ដូងទឹកស្អាតចំនួន០២កន្លែង សម្ពោធធ្នង់ឧបដ្ឋានសាលា និងសមិទ្ធផលនានា ព្រមទាំងកម្មវិធីផ្សេងៗ នៅខេត្តកំពង់ចាម កំពង់ស្ពឺ ក្រចេះ តាកែវ កណ្ដាល និងរាជធានីភ្នំពេញ<br>- បានរៀបចំទីកន្លែងសម្រាប់សិក្ខាសាលា និងពិធីផ្សេងៗចំនួន០៩លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២០៦នាក់ ស្មើនឹង៧៨ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភាចំនួន១៤រូប ស្មើនឹង១៤ច្បាប់<br>- បានថតចម្លងឯកសារបានចំនួន៥៦៩ច្បាប់ អស់ក្រដាសចំនួន១,៦២៥សន្លឹក |

រដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ដើម្បី
អបអរសាទរខួបអនុស្សាវរីយ៍លើកទី៦០
នៃទំនាក់ទំនងការទូត និងសហប្រតិបត្តិការ
កម្ពុជា- ចិន នៅមជ្ឈមណ្ឌលកោះពេជ្រ

+ អញ្ជើញពិសាអាហារសាមគ្គី ដែលបាន
រៀបចំដោយសមាគមមិត្តភាពកម្ពុជា- ចិន
និងស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន
នៅភោជនីយដ្ឋានឡៅទីហ្វាង

- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន
០៣ករណី កំពុងពិនិត្យសិក្សាចំនួន០៣ករណី
ព្រមទាំងទទួលការឆ្លើយតបអំពីការដោះស្រាយ
ពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន០២ករណី
និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០២ករណី

- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញ
ចុះតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញ
ទូទាំងប្រទេសចំនួន៤៥០លើក ដើម្បីជួប
ពិភាក្សាការងារ សំណេះសំណាល សាកសួរ
សុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុម
ប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត
ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ
ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផល
នានា តាមដានការអនុវត្តគោលនយោបាយ
វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ
ការអនុវត្តគោលនយោបាយភូមិ ឃុំ មាន
សុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាព
សិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវា
សាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន
និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ
ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធី

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ
សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ
នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តា
ខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន២៣៣នាក់
ស្មើនឹង៨២លើក

- បានទទួលលិខិតចូលចំនួន៨៨៨ច្បាប់

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក
សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-
ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយ
ផ្សេងៗចំនួន៩៦លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់
ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខ
ផ្ទៃក្នុងចំនួន១៥នាក់ ស្មើនឹង០៥លើក

- បានចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០៣លើក

- បានចុះសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋាន
ព្រឹទ្ធសភាចំនួន០៥នាក់

- បានផ្តល់អត្ថបទព័ត៌មាន និងរូបថតចំនួន
១,១៣៩សន្លឹក ជូនអង្គភាពចំណុះអគ្គលេខា-
ធិការដ្ឋានព្រឹទ្ធសភា

- បានបោះពុម្ពសៀវភៅបត់ស្តីពី ព្រឹទ្ធសភា នីតិ-
កាលទី២

- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និង
សាធារណជនចូលអានសៀវភៅចំនួន២៨០នាក់
អនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន២៨ក្បាល និង
សងវិញចំនួន២៧ក្បាល ព្រមទាំងបានធ្វើកាត
សមាជិកបណ្ណាល័យជូនសិស្ស និងនិស្សិត
ចំនួន១៥នាក់

- បានទទួលឯកសារ សៀវភៅ ព្រឹត្តិបត្រ ទស្សនាវដ្តី
ព្រះរាជក្រមចំនួន១៤៧ក្បាល កាសែតចំនួន

| | |
|---|---|
| ផ្សេងៗសរុបចំនួន៨៩លើក។ | ១៦៧ច្បាប់ និងCDចម្រៀងវប្បធម៌ខ្មែរចំនួន០៨ដុំ ពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- កំពុងរៀបចំផលិតសៀវភៅនិនានុលេខន៍ និងសៀវភៅបត់ស្តីពី ព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៩<br>- បានរៀបចំទស្សនាវដ្តីប្រចាំខែមិថុនា ឆ្នាំ២០១៨<br>- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភាចំនួន១៣៨លើក<br>- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៥២លើក<br>- បានចងក្រងសៀវភៅពាក់ព័ន្ធនឹងសកម្មភាព និងសមិទ្ធផលរបស់ក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទាំង៨ សម្រាប់នីតិកាលទី៣ (២០១២-២០១៨)<br>- បានធ្វើបច្ចុប្បន្នភាពស្ថិតិ ទិន្នន័យ សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤<br>- បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សានៅព្រឹទ្ធសភាចំនួន០១លើក របស់សាស្ត្រាចារ្យ និងនិស្សិត មកពីសាកលវិទ្យាល័យប៊ែលជីអន្តរជាតិចំនួន២០០នាក់។ |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានទទួលជួបសម្តែងការគួរសមជាមួយក្រុមអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិចំនួន៤៥នាក់ និងអ្នកសង្កេតការណ៍បោះឆ្នោតសហព័ន្ធរុស្ស៊ី និងក្រុមមិត្តភាពរុស្ស៊ី | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អង្គទូត និងអង្គការអន្តរជាតិនានា<br>- បានរៀបចំទីកន្លែងសម្រាប់ជំនួបសម្តែងការគួរសមចំនួន០២លើក |

| | |
|---|---|
| ព្រមទាំងក្រុមមិត្តភាពកម្ពុជា និងរុស្ស៊ី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអនុញ្ញាតឱ្យអ្នកស្ម័គ្រចិត្ត និងកម្មសិក្សាការីជនជាតិបារាំង នៃការិយាល័យហ្វ្រង់កូហ្វូនីព្រឹទ្ធសភា និងលោកYamamoto Masaki ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ<br>- សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមមហាសន្និបាតលើកទី៤៤ នៃសភានិយាយភាសាបារាំង(APF) នៅប្រទេសកាណាដា និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកការងារសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព នៅសាធារណរដ្ឋស៊ីប។ | - បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវជាតិ និងអន្តរជាតិ មកបំពេញទស្សនកិច្ចនៅព្រឹទ្ធសភាចំនួន០៧លើក<br>- បានរៀបចំសម្អាត តុបតែងសាល និងបម្រើភេសជ្ជៈក្នុងកិច្ចប្រជុំចំនួន០៤លើក<br>- បានថតចម្លងឯកសារចំនួន១១៤ច្បាប់ អស់ក្រដាសចំនួន១១,៣៤៥សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៨០នាក់ ស្មើនឹង២៦លើក<br>- បានធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូតសំណើ និងលិខិតឆ្លើយតបទៅក្រសួង ស្ថាប័នផ្សេងៗ និងបណ្តាអង្គទូតនានាចំនួន១៦លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៤នាក់ ស្មើនឹង០៦ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១១លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៦៧នាក់ ស្មើនឹង០៣លើក<br>- បានរៀបចំបែបបទជូនគណៈប្រតិភូសមាជិកព្រឹទ្ធសភា អញ្ជើញទៅចូលរួមមហាសន្និបាត និងចូលរួមកិច្ចប្រជុំ នៅក្រៅប្រទេសចំនួន០២លើក<br>- បានរៀបចំបែបបទជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅទស្សនកិច្ចសិក្សា |

| | |
|---|---|
| | ចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាចំនួន០៥លើក<br>- បានទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន **និង** បណ្ណាល័យនានា ដើម្បីសុំ និងទទួលសៀវភៅ ព្រឹត្តិបត្រ និងសម្រួលដល់កិច្ចការ**អន្តរជាតិ** ដំណើរទស្សនកិច្ច សិក្ខាសាលា បេសកកម្ម ក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | + បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៩៦ច្បាប់<br>- រៀបចំចងក្រងសម្រង់ស្ថិតិ បទបង្ហាញ របាយ-ការណ៍ស្តីពី សកម្មភាពការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែកក្កដា ឆ្នាំ២០១៨ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២៧០ច្បាប់<br>- បានប្រជុំបូកសរុបប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០១៨។<br>+ ការងារគ្រប់គ្រងបុគ្គលិក:<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៣២ច្បាប់<br>- ប្រជុំគណៈកម្មការគ្រប់គ្រងដំណើរការវាយតម្លៃបន្តកិច្ចសន្យាដល់បុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានធ្វើបែបបទស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី |

| | |
|---|---|
| | ការកិច្ច និងសមត្ថកិច្ចនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។<br>+ **ការងារបណ្តុះបណ្តាលធនធានមនុស្ស:**<br>- ការបណ្តុះបណ្តាលធនធានមនុស្សក្នុង និងក្រៅប្រទេសចំនួន០៦វគ្គ មានសិក្ខាកាមសរុបចំនួន ២១នាក់។<br>+ **ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:**<br>- បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ប្រជុំរៀបចំគោលការណ៍ហិរញ្ញវត្ថុសម្រាប់នីតិកាលទី៤ ព្រឹទ្ធសភា<br>- ប្រជុំថ្លឹងគម្រោងថវិកាឆ្នាំ២០១៩ របស់ព្រឹទ្ធសភា ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងកម្រិតបច្ចេកទេស<br>- រៀបចំរបាយការណ៍ចំណូល និងចំណាយថវិកាប្រចាំឆមាសទី១ របស់ព្រឹទ្ធសភា<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្សប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែ ព្រមទាំងធ្វើតារាងប្រាក់ឧបត្ថម្ភរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំនានាចំនួន ២០សំណើ បានផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ និងភេសជ្ជៈចំនួន៥៨សំណើ |

| | |
|---|---|
| | សម្រាប់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំសម្អាត តុបតែងសាល ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់ ក្នុងពិធីផ្សេងៗចំនួន២២លើក មានអ្នកចូលរួមចំនួន៦៥២នាក់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន១២៨លើក<br>- បានថតចម្លងឯកសារចំនួន៦,៥០៨ច្បាប់ និងចងក្រងសៀវភៅចំនួន១៣៦ក្បាល អស់ក្រដាសចំនួន៤៩,៤៦២សន្លឹក និងជួសជុលសម្អាតម៉ាស៊ីនថតចម្លងចំនួន១៦លើក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ក្នុងរាជធានីភ្នំពេញចំនួន ១៩នាក់ ស្មើនឹង១៤លើកៗ<br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់ :<br>- បញ្ចប់ការសាងសង់អគារថ្មី០១ខ្នង និងបានដាក់ដំណើរការសម្រាប់ជាការិយាល័យធ្វើការរបស់គណៈកម្មការទី១០ គណៈកម្មការក្រមសីលធម៌ និងក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ<br>- បញ្ចប់ការសាងសង់ឃ្លាំងថ្មី នៅខាងក្រោយអគារE<br>- ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារៈសារពើភ័ណ្ឌ និងបែងចែកកុំព្យូទ័រលើតុសរុបចំនួន១៣៩គ្រឿង |

| | |
|---|---|
| | - រៀបចំសួនច្បារជុំវិញអគារគណៈកម្មការទី១០ថ្មី និងកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភាឱ្យមានសោភ័ណភាពល្អ<br>- បន្តរៀបចំបំពាក់អំពូលប្រើដោយថាមពលព្រះអាទិត្យក្នុងបរិវេណព្រឹទ្ធសភា<br>- បានតាំងពិព័រណ៍រូបភាព និងធ្វើហ្វុងអក្សរចំនួន ០២លើក<br>- សហការជាមួយក្រុមហ៊ុនកំចាត់សត្វកណ្ដៀរ និងសហការប្រចាំការម៉ាស៊ីនភ្លើង នៅតាមសាលប្រជុំ ព្រមទាំងបានត្រួតពិនិត្យមើលការប្រើប្រាស់ទឹកភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាក សរុបចំនួន៥០លើក<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និង Set up កម្មវិធីសរុបចំនួន៨២គ្រឿង។ បានUpload សេចក្ដីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្ដី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាសរុបចំនួន២៤ចំណងជើង។<br>+ ការងារផ្សេងៗ :<br>- បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតខ្សែវីដេអូ សម្រាប់បង្ហោះលើ Alert Newsចំនួន ១៥៦ប្រធានបទ<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗចំនួន៣៩លើក<br>- បានចុះបញ្ជីសៀវភៅ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ អ៊ុតក្របសៀវភៅ ដាក់លេខកូដសៀវភៅ បញ្ចូលសៀវភៅភាសាអង់គ្លេសក្នុង |

| | |
|---|---|
| | កម្មវិធី KOHA និងបញ្ជូនសៀវភៅដាក់នៅសាលអាន ព្រមទាំងជួសជុលឯកសារ និងសៀវភៅចាស់ៗសរុបចំនួន៥៥៨ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្ដី ព្រឹត្តិបត្រ រាជកិច្ច និងបញ្ចូលសៀវភៅតាម E-Library បណ្ដាញ Facebook សរុបចំនួន៦,៣៦០ក្បាល។ |

II.**ទិសដៅការងារខែសីហា ឆ្នាំ២០១៨**

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួង ស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា

-ត្រៀមទទួលដំណើរទស្សនកិច្ចរបស់អគ្គលេខាធិការព្រឹទ្ធសភានៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទៅបំពេញបេសកកម្មក្រៅប្រទេស

-ការចូលរួមវេទិកា ALFOCOM និងវេទិកា APPF នាខែមករា ឆ្នាំ២០១៩ នៅខេត្តសៀមរាប

-ការចូលរួមមហាសន្និបាត AIPA នាខែកញ្ញា នៅសាធារណរដ្ឋសិង្ហបុរី

-ការចូលរួមកិច្ចប្រជុំប្រធានសភាអាស៊ី-អឺរ៉ុប នៅប្រទេសតួកគី

-ការចូលរួមកិច្ចប្រជុំកំពូលនៃក្របខ័ណ្ឌជាដៃគូសភាអាស៊ី-អឺរ៉ុប ASGP នៅប្រទេសព្រុចសែល

-ការចូលរួមមហាសន្និបាត IPU និង ASGP នាខែតុលា នៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស

-ត្រៀមរៀបចំដំណើរទស្សនកិច្ចផ្លូវការក្នុងឱកាសខួបទី៦០ឆ្នាំ នៃទំនាក់ទំនងការទូត នាខែតុលា នៅសាធារណរដ្ឋប្រជាមានិតចិន និងទស្សនកិច្ចផ្លូវការនៅបារាំង

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា

-ត្រៀមអនុវត្តន៍កម្មវិធីជាមួយ(APF)

-ត្រៀមចូលរួមវគ្គបណ្តុះបណ្តាលនានា ដែលចាត់ចែងដោយវិទ្យាស្ថានសភាកម្ពុជា(PIC)។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-ការងារតាមដានការសុំជំនួយពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមមានការកសាងអគារសាលប្រជុំពេញអង្គថ្មី

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV-online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpageក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាលក្នុងនោះចូលអនុវត្តកម្មវិធី Eបណ្ណាល័យ និង E បណ្ណសារ

-អនុវត្តគម្រោងបច្ចុប្បន្នភាពរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាតាមតម្រូវការថ្មី

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធតួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តការសិក្សាអំពីការបង្កើតអគ្គនាយកដ្ឋានស្រាវជ្រាវ និងអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ទំនាក់ទំនងជាថ្មីជាមួយភាគីវៀតណាម ដើម្បីបន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) និងការបំពាក់សម្ភារៈបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀតឆ្នាំ២០១៨

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការ

-ត្រៀមការពារគម្រោងថវិកាឆ្នាំ២០១៩ របស់ព្រឹទ្ធសភា ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្រិតនយោបាយ

-ត្រៀមរបាយការណ៍ទូទាត់ថវិកាចំណាយឆមាសទី១ ឆ្នាំ២០១៨ របស់ព្រឹទ្ធសភា ជូនគណៈ-កម្មាធិការអចិន្ត្រៃយ៍

-ការត្រៀមរៀបចំកសាងថវិកាកម្មវិធីឆ្នាំ២០១៩ និងរបាយការណ៍វាយតម្លៃចំណាយថវិកាឆមាសទី១ ឆ្នាំ២០១៨ របស់អង្គភាពចំណាយ។

III.**សេចក្តីសន្និដ្ឋាន**

ខែកក្កដានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ មុខងារតំណាង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាបានដោយរលូន។ ជោគជ័យនៃការចូលរួមក្នុងមហាសន្និបាតលើកទី៤៤នៃសមាគមសភាប្រើប្រាស់ភាសាបារាំងAPF និងសមាគមអគ្គលេខាធិការនៃសភាប្រើភាសាបារាំង ASGP បានលើកកម្ពស់កិត្យានុភាពប្រទេសជាតិ អង្គការនិតិប្បញ្ញត្តិកម្ពុជា ព្រមទាំងព្រឹទ្ធសភាយើង។ ចំពោះមុខងារអភិវឌ្ឍន៍ស្ថាប័ន បានបន្តយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្សបង្កើនសមត្ថភាពស្រាវជ្រាវភាសាបរទេសកាន់តែមានតម្រូវការធំជាងមុនដែលត្រូវខិតខំឆ្លើយតបឱ្យបានល្អប្រសើរ។ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ដើម្បីធានាបាននូវសេវាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់ជូនអតិថិជនរបស់ខ្លួន។ ចំណែកមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានបន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់បម្រើឱ្យព្រឹទ្ធសភានីតិកាលទី៤ ដំណើរការកាន់តែល្អប្រសើរ។ ព្រឹទ្ធសភានីតិកាលទី៤ ត្រូវដើរតួជំនួសមុខអង្គការនីតិប្បញ្ញត្តិកម្ពុជាក្នុងក្របខ័ណ្ឌ AIPA, APF និងIPU នាពេលខាងមុខៗ ការកសាងបាននូវអគារថ្មីបន្ថែម បានរួមចំណែកដ៏សំខាន់ក្នុងការដោះស្រាយទីកន្លែងធ្វើការងារឱ្យបានកាន់តែសមរម្យថែមទៀត។

គ្រប់យន្តការបានដំណើរការ និងកសាងជាបណ្តើរៗនូវផែនការយុទ្ធសាស្ត្រប្រចាំនីតិកាលទី៤ និងកម្មវិធីការងារប្រចាំឆ្នាំ ឆមាស ត្រីមាស និងប្រចាំខែ ដើម្បីអនុវត្តថវិកាកម្មវិធីឱ្យបានល្អប្រសើរ។/.

ថ្ងៃ ៣ ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨

**អគ្គលេខាធិការស្តីទី**

ឡោក_ឆាយ